**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៥៦៦ សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការគ្រប់គ្រងចំណូលពីការលក់លេខចុះបញ្ជីរថយន្ត

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Duan Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៨៦៣ សហវ.ប្រក ចុះថ្ងៃទី.១៩.. ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ លើលិខិតរួមចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូនស្តីពីការរៀបចំប្រកាសរួម ដើម្បីប្រមូលចំណូលពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល។

## សម្រេច

**ប្រការ១ .-**

ប្រគល់សិទ្ធិជូនអគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន (អគ្គនាយកដ្ឋានដឹកជញ្ជូន) ទទួលខុសត្រូវលើការគ្រប់គ្រងប្រាក់ចំណូលប្រមូលបានពីការលក់លេខចុះបញ្ជីរថយន្ត ដែលកំណត់ដោយប្រកាសរួមលេខ.៨៦៣ សហវ.ប្រក ចុះថ្ងៃទី.១៩.. ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល។

**ប្រការ២ .-**

អនុញ្ញាតឱ្យអគ្គនាយកដ្ឋានដឹកជញ្ជូន បើកគណនីប្រាក់បញ្ញើជាប្រាក់រៀលនៅធនាគារឯកទេសរីង ឬធនាគារពាណិជ្ជណាមួយ ដើម្បីប្រមូលផ្តុំប្រាក់ចំណូលពីការលក់លេខចុះបញ្ជីរថយន្ត នៅទូទាំងរាជធានី ខេត្ត ទាំង ២៥ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើសេចក្តីជូនដំណឹងឱ្យបានច្បាស់លាស់ដល់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអតិថិជន ស្តីពីការបង់ប្រាក់ និងការទទួលប្រាក់ថ្លៃទិញលេខចុះបញ្ជីរថយន្ត ដែលត្រូវធ្វើឡើងនៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឬ តម្រូវឱ្យអតិថិជនបង់ប្រាក់ចូលគណនីនៅធនាគារឯកទេសរីង ឬ ធនាគារពាណិជ្ជណាមួយ ដែលបានកំណត់។

ប្រការ៤ .-

អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលស្តីពីការអនុវត្តចំណូលប្រចាំខែ គោរពជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់ ដោយភ្ជាប់ជាមួយរបាយការណ៍របស់ធនាគារឯកទេសរីឯ ឬ ធនាគារពាណិជ្ជ។

ប្រការ៥ .-

រាល់ការចាត់ចែងប្រាក់ចំណូលដែលប្រមូលបានពីការលក់លេខចុះបញ្ជីរថយន្ត ត្រូវអនុវត្តតាមនីតិវិធីដូចតទៅ ÷

ក- ផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូលជាក់ស្តែងប្រចាំត្រីមាសនីមួយៗ អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើសំណើសុំគោលការណ៍សម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការអនុវត្តលើមុខចំណាយដូចខាងក្រោម ÷

- បង់វិភាគទានឧបត្ថម្ភមូលនិធិកាត់បន្ថយភាពក្រីក្រ (៦០% នៃចំណូលប្រមូលបានសរុប)
- ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីរាជការបម្រើការងារផ្ទាល់ និងមន្ត្រីរាជការបំពេញភារកិច្ចពាក់ព័ន្ធ ព្រមទាំងចំណាយពង្រឹងយន្តការប្រមូលចំណូល
- បង់ចំណូលចូលថវិការដ្ឋ។

ខ- បន្ទាប់ពីទទួលបានគោលការណ៍សម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវអនុវត្តការចំណាយឱ្យបានត្រឹមត្រូវ និងធ្វើរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល ចំណាយជាក់ស្តែង គោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានជូនភ្ជាប់ជាមួយនូវសក្ខីប័ត្រចំណាយពាក់ព័ន្ធ។

គ- នៅរៀងរាល់ដំណាច់ឆ្នាំ អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលស្តីពីស្ថានភាពនៃការអនុវត្តចំណូល ចំណាយប្រចាំឆ្នាំ គោរពរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រការ៦ .-

រាល់របាយការណ៍ស្តីពីការអនុវត្តចំណូល ការស្នើសុំចាត់ចែងប្រាក់ចំណូល និងរបាយការណ៍ផ្សេងៗទៀត អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវភ្ជាប់ជាមួយកំណត់បង្ហាញរឿងតាមទម្រង់ដូចមានជូនភ្ជាប់នឹងប្រកាសរួមនេះ។

ប្រការ៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៨ ._

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសាធារណការ និងដឹកជញ្ជូន
រដ្ឋមន្ត្រី

តូច ចាន់កុសល

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ